00897894 E279

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2013, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់អំពីកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយ**
**ដែលបានដាក់បញ្ចូលក្នុងសេចក្តីប្រកាសបំបែកកិច្ចដំណើរការនីតិវិធី**
**ក្រោយថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣**

---

<u>អ្នកដាក់ឯកសារ:</u>

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

<u>អ្នកទទួលឯកសារ:</u>

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

<u>ចម្លងជូន:</u>

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

ក្រុមមេធាវីការពារក្តី:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
Jacques VERGES
Arthur VERCKEN
Anta GUISSE

# សំណើ

១- ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសពីចេតនារបស់ខ្លួនដើម្បីបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ដោយកំណត់វិសាលភាពនៃការជំនុំជម្រះត្រឹមបទចោទដែលពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ (ដំណាក់កាលទី១ និង ទី២) និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[1]។ ដោយសារការផ្តល់សក្ខីកម្មសាក្សីត្រូវបានកំណត់ពេលធ្វើបន្តនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ហើយដែលអង្គជំនុំជម្រះសាលាដំបូង នៅមិនទាន់បានចេញសេចក្តីសម្រេចជាលាយល័ក្ខណ៍អក្សររបស់ខ្លួននៅឡើយ ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី ការិយាល័យសហព្រះរាជអាជ្ញាបានផ្ញើអ៊ីម៉ែលមួយទៅមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៣ ដោយស្នើសុំការបញ្ជាក់ថាតើ កថាខណ្ឌដូចគ្នានៃដីកាដំណោះស្រាយនៃសំណុំរឿង០០២ ដែលបានដាក់បញ្ចូលពីមុនក្នុងសំណុំរឿង ០០២/១[2] នោះឬ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដែលបានបំបែកជាថ្មីនេះ។ ក្នុងអ៊ីម៉ែលមួយដែលបានបញ្ជូនទៅគ្រប់ភាគីកាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ នៅមុនការចាប់ផ្តើមការផ្តល់សក្ខីកម្ម មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់បានបញ្ជាក់អះអាងថា "កថាខណ្ឌនានានៃដីកាដំណោះស្រាយជាធរមាន គឺជាកថាខណ្ឌទាំងឡាយណាដែលបានកំណត់អត្តសញ្ញាណពីមុនទាក់ទងនឹងការជម្លៀសដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ដូចបានរៀបរាប់ក្នុងឯកសារ E124/7.3"។

២- សហព្រះរាជអាជ្ញាសូមស្នើបន្ថែមដើម្បីឲ្យអង្គជំនុំជម្រះបំភ្លឺអំពីវិសាលភាពនៃការចោទប្រកាន់ និងបទចោទទាក់ទងនឹងការជម្លៀសដោយបង្ខំចំពោះប្រជាជនចាម ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដែលបានបំបែកជាថ្មីនេះ។ ការចោទប្រកាន់ទាក់ទងនឹងការជម្លៀសជនជាតិចាម ត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង០០២/១ ពីមុនរួចហើយ។ ជាឧទាហរណ៍ កថាខណ្ឌទី២៦៦ នៃដីកាដំណោះស្រាយចោទថាៈ "ជនជាតិចាមមួយចំនួនក៏ស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានផ្លាស់ទីលំនៅដែរ ដោយការផ្លាស់ទីលំនៅប្រជាជនចាមទាំងនេះកើតឡើងនៅចុងឆ្នាំ១៩៧៥ បន្ទាប់ពីមានការបះបោររបស់ជនជាតិចាម នៅទីតាំងពីរកន្លែងនៅក្នុងភូមិភាគបូព៌ា។ ជនជាតិចាមជាច្រើនត្រូវបានផ្លាស់ទីលំនៅពីភូមិកំណើតរបស់ខ្លួននៅក្នុងខេត្តកំពង់ចាម ហើយត្រូវបានបញ្ជូនទៅភូមិផ្សេងៗ

---

[1] **E1/176.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៩ មីនា ២០១៣, ទំព័រទី៤ (09:11:10)។

[2] **E124/7.3** បញ្ជីកថាខណ្ឌ និងចំណែកនៃដីកាដំណោះស្រាយដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១, ដែលបានធ្វើវិសោធនកម្មបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១ (E163)។

ទៀតនៅក្នុងខេត្តដដែលនេះ។ អ្នកខ្លះទៀតត្រូវបានបញ្ជូនទៅឆ្ងាយទៅភូមិនានា ទូទាំងខេត្តក្រចេះ កំពង់ធំ និងបាត់ដំបង។ ទូរលេខ១៥ និងភ័ស្តុតាងផ្សេងទៀតដែលបានបន្សល់ទុកបានឲ្យដឹងថា ការសម្រេចមួយត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ហើយក្រោយមកត្រូវបានអនុវត្ត ដើម្បីផ្លាស់ទីលំនៅប្រជាជនចាមរាប់ពាន់នាក់នៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ”[3]។

៣- កថាខណ្ឌ ២៦៨ នៃដីកាដំណោះស្រាយបានចោទប្រកាន់ថា៖ “សាក្សីមួយចំនួនបានរៀបរាប់ថា ប្រជាជនចាមត្រូវបានបំបែកទៅតាមភូមិខ្មែរ ដោយមានតែប្រជាជនចាមមួយចំនួនតូចប៉ុណ្ណោះត្រូវបានអនុញ្ញាតឲ្យរស់នៅតាមភូមិនីមួយៗ។ សក្ខីកម្មនានាបង្ហាញថា ជនជាតិចាមជា បុរស ស្ត្រី និង កុមារ ត្រូវបានបំបែកពីគ្នា ហើយផ្លាស់ទីលំនៅទៅទីផ្សេងៗគ្នា ...។ សាក្សីបីរូបបាននិយាយ ថា ពួកគេត្រូវបានតម្រូវឲ្យរស់នៅខាងក្រោមផ្ទះប្រជាជនខ្មែរ។ សាក្សីពីររូបនិយាយថា មនុស្សចាស់ជនជាតិចាម និងមេដឹកនាំសាសនានៅក្នុងភូមិរបស់ខ្លួន ត្រូវបានចាប់ខ្លួន និងសម្លាប់មុនពេលការផ្លាស់ទីលំនៅរបស់ប្រជាជនបានចាប់ផ្តើម”[4]។ និងកថាខណ្ឌ ២៨១ បានចោទប្រកាន់ដូចតទៅ៖ “ទូរលេខ ១៥ បង្ហាញជាសំខាន់អំពីបញ្ហាមួយដែលកើតឡើងពីការផ្លាស់ទីលំនៅ ប្រជាជនចាម [ចេញពីភូមិភាគបូព៌ា]។ ហេតុការណ៍នេះកើតឡើងប៉ុន្មានសប្តាហ៍បន្ទាប់ពីការ បះបោររបស់ប្រជាជនចាមនៅកោះផល និងស្វាយឃ្លាំង។ នៅក្នុងបរិបទដូច្នេះ ភ័ស្តុតាងនេះអាចបង្ហាញថា មូលហេតុចម្បងចំពោះការផ្លាស់ទីកន្លែង និងការបំបែកប្រជាជនចាមតាមការគ្រោងទុក គឺជាការកំណត់ពីបញ្ហាគំរាមកំហែងផ្នែកសន្តិសុខដែលបានអនុវត្តចំពោះប្រជាជនចាម ព្រមទាំងជាការឆ្លុះបញ្ចាំងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បី “បំបែក” ប្រជាជនចាម[5]។

៤- ខណៈដែលការចោទប្រកាន់នានាខាងលើនេះ ដែលមានការពាក់ព័ន្ធនឹងជនជាតិចាម ត្រូវបានដាក់បញ្ចូលទៅក្នុងវិសាលភាពលើកមុនក្នុងសំណុំរឿងលេខ០០២/០១ បទចោទនានាស្តីពីការធ្វើទុក្ខបុកម្នេញខាងសាសនា ត្រូវបានផាត់ចេញយ៉ាងជាក់លាក់ពីបទល្មើសពាក់ព័ន្ធជាមូលដ្ឋាន[6]។ ដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់ថា បទចោទតែមួយដូចគ្នា ពាក់ព័ន្ធ

---

[3] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, កថាខណ្ឌ២៦៦ *[កំណត់សម្គាល់ជើងទំព័រត្រូវបានលុបចេញ]*។

[4] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ២៦៨ *[កំណត់សម្គាល់ជើងទំព័រត្រូវបានលុបចេញ]*។

[5] **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ២៨១ *[កំណត់សម្គាល់ជើងទំព័រត្រូវបានលុបចេញ]*។

[6] **E124/7.3** បញ្ជីកថាខណ្ឌ និងផ្នែកផ្សេងៗនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០២/០១, កថាខណ្ឌទី៤, កំណត់សម្គាល់ជើងទំព័រ លេខ១។

នឹងការជម្លៀសប្រជាជនចាមដោយបង្ខំ និងគោលនយោបាយរបស់ ប.ក.ក ក្នុងការបំបែកជនជាតិចាម ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃសវនាការដែលបានបំបែកកិច្ចដំណើរការនីតិវិធីថ្មីនេះឬទេ និងសូមឱ្យបញ្ជាក់ឱ្យបានច្បាស់ផងដែរ ថាតើការចោទប្រកាន់តាមអង្គហេតុទាំងនោះ ត្រូវស្ថិតនៅក្រោមកម្មវត្ថុជាសក្ដានុពលនៃការកំណត់បទចោទ ដូចគ្នានឹងការធ្វើទុក្ខបុកម្នេញខាងសាសនា អនុលោមតាមសិទ្ធិអំណាចរបស់អង្គជំនុំជម្រះ ដូចមានចែងក្នុងវិធាន៩៨(២) ដែរ ឬទេ។

៥- សហព្រះរាជអាជ្ញាក៏កត់សម្គាល់ផងដែរថា ពុំទាន់មានការស្ដាប់សាក្សីណាម្នាក់នៅឡើយទាក់ទងនឹងការជម្លៀសប្រជាជនចាមដោយបង្ខំ។ កន្លងមក អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានដាក់បញ្ចូលសាក្សី TCCP-215 (TCW-674) ជាសាក្សីបម្រុង ទាក់ទងនឹងការជម្លៀសដោយបង្ខំ[7]។ សហព្រះរាជអាជ្ញាសូមស្នើថា គួរមានសវនាការស្ដាប់ចម្លើយសាក្សី TCCP-215 និងសូមស្នើបន្ថែមឱ្យ អង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សី TCW-269 ផងដែរចំពោះបញ្ហាទាំងនេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[7] **E236/1** ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មនៅក្នុងអម្លុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ក្នុងសំណុំរឿងលេខ ០០២/០១ , ២ តុលា ២០១២។